german cooperation
DEUTSCHE ZUSAMMENARBEIT

Implemented by:

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

WORKER'S INFORMATION CENTER



# LIFE THROUGH OUR EYES
# ខ្សែជីវិតតាមរយៈចក្ខុវិញ្ញាណរបស់យើង

By Cambodian garment workers

ដោយកម្មការនី រោងចក្រនៅកម្ពុជា



Nine women working in the garment industry share their view of life.
ស្ត្រី០៩រូបធ្វើការនៅក្នុងវិស័យរោងចក្រកាត់ដេរចូលរួមចែករំលែកអំពីទស្សនៈនៃជីវិតរស់នៅតាមរយៈរូបភាពរបស់ពួកគេ ។

# LIFE THROUGH OUR EYES
# ខ្សែជីវិតតាមរយៈចក្ខុវិញ្ញាណរបស់យើង

By Cambodian garment workers

ដោយកម្មការនី  រោងចក្រនៅកម្ពុជា

Photo Exhibition: 11 – 31 March 2018

Meta House / German Cambodian Cultural Center

តាំងពិព័រណ៍រូបភាព ៖ ថ្ងៃទី១១ - ៣១ ខែមីនា ឆ្នាំ២០១៨

មេតា ហៅស៍ (មណ្ឌលវប្បធម៌អាឡឺម៉ង់-កម្ពុជា)

# LIFE THROUGH OUR EYES

By Cambodian garment workers

The textile and garment industry in Asia creates millions of jobs and is a key factor for economic prosperity in many Asian countries. By securing income for many, mostly female workers, the industry has the potential to reduce poverty, empower women and drive development. On the negative side, working conditions do not always meet international standards and the industry holds a risk of exploitation.

By now, the working and living conditions of the workers in the textile and garment industry are known to the globalized world by two types of relatively homogeneous pictures circulating in the media: Many photos present concentrated, motivated female garment workers. By contrast, the others show workers who are injured, killed or protesting for their rights.

What these pictures do not show is the very heterogeneous realities in the daily lives of the garment workers. How are they seeing their reality? What issues related to their living and working conditions are they considering being important? How do they want to be represented to the outside world?

To enable female workers to tell their own story and thus for moving beyond stereotypes, the GIZ programme Social and Labour Standards in the Textile and Garment Sector in Asia (SLSG) in cooperation with the Workers' Information Center (WIC) implemented a Participatory Photography Project.

Nine women working in the garment industry were shown by acclaimed photographer Andrea Diefenbach, how they can use photography as a tool for communication. They developed picture series that reflect on their life situation, revealing their look at the world and picturing their thoughts, emotions and dreams. Through these pictures, the audience can see life through their eyes, and the women have a tool for advocacy at hand which serves as a catalyst for social change to their advantage.

# ខ្សែជីវិតតាមរយៈចក្ខុវិញ្ញាណរបស់យើង

ដោយកម្មការនី រោងចក្រនៅកម្ពុជា

វិស័យវាយនភ័ណ្ឌនិងរោងចក្រនៅតំបន់អាស៊ីបង្កើតអោយមានការងាររាប់លាន ហើយក៏ជាកត្តាចម្បងនៃការរីកចំរើនសេដ្ឋកិច្ចនៅតាមប្រទេសជាច្រើនក្នុងតំបន់អាស៊ី ។ ដោយបង្កើតអោយមានចំនូលជាប្រចាំសំរាប់មនុស្សជាច្រើន ដែលភាគច្រើនជាកម្មការីនី វិស័យនេះមានសក្តានុពលជួយកាត់បន្ថយភាពក្រីក្រ ពង្រឹងស្ត្រី និងដឹកនាំទៅរកការអភិវឌ្ឍន៍ ។ បើមើលពីជ្រុងអវិជ្ជមានលក្ខខណ្ឌនៃការធ្វើការងារមិនត្រូវបានគោរពទៅតាមស្តង់ដារអន្តរជាតិនៅឡើយ ហើយវិស័យនេះក៏បានទាញផលចំណេញយ៉ាងច្រើនពីកម្មករនិយោជិត ។

មកដល់ពេលបច្ចុប្បន្ននេះ លក្ខខណ្ឌនៃការងារ និងជីវភាពរស់នៅក្នុងវិស័យវាយនភ័ណ្ឌ និងរោងចក្រត្រូវបានដឹងឮទូទាំងសាកលលោកតាមរយៈ រូបភាពពីរប្រភេទផ្សេងគ្នាដែលពាក់ពន្ធ័ និងវិស័យនេះហើយតែងតែចរាចរណ៍លើប្រព័ន្ធផ្សព្វផ្សាយ ៖មានរូបភាពជាច្រើនបង្ហាញពីកម្មការីនីដែលពោរពេញដោយការផ្តោតអារម្មណ៍យកចិត្តទុកដាក់ និងក្តីសង្ឃឹម ផ្ទុយទៅវិញក៏មានបង្ហាញនូវរូបភាពដែលកម្មករនិយោជិតត្រូវបានសម្លាប់ និងរងរបួស ឬ រូបភាពនៃបាតុកម្មរបស់កម្មករនិយោជិតដើម្បីទាមទារសិទ្ធិរបស់ពួកគេ ។

អ្វីដែលរូបភាពទាំងនេះមិនបានបានបង្ហាញគឺជាការពិតនៃជីវិតប្រចាំថ្ងៃរបស់កម្មករនិយោជិត ។ តើពួកគេអាចមើលឃើញការពិតនៃជីវិតរបស់ពួកគេដោយរបៀបណា? តើអ្វីជាបញ្ហាពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃការរស់នៅ និងលក្ខខណ្ឌនៃការងារដែលពួកគេគិតថាមានសារៈសំខាន់? តើពួកគេចង់បង្ហាញអ្វីទៅដល់ពិភពលោកខាងក្រៅ?

ដើម្បីជួយអោយស្ត្រីជាកម្មករបង្ហាញនូវរឿងរ៉ាវផ្ទាល់ខ្លួនរបស់ពួកគេ ដោយជៀសវាងនូវការផ្តោតលើរឿងតែមួយ ប៉ុន្តែជារឿងរ៉ាវដែលមានលក្ខណៈខុសៗគ្នានៃកម្មករនិយោជិត ដូច្នេះគម្រោងវាយនភ័ណ្ឌនិងបទដ្ឋានសង្គម (SLSG) នៃ GIZ បានសហការជាមួយសមាគមមណ្ឌលពត៌មានកម្មករ(WIC) អនុវត្តនូវគម្រោងរូបភាពតាមបែបនៃការចូលរួម (Participatory Photography Project) ។

ស្ត្រី០៩រូបធ្វើការនៅក្នុងវិស័យរោងចក្រដែលបានដឹកនាំដោយអ្នកថតរូប លោកស្រី អ៊ែនឌ្រា ឌីហ្វេនបាច (Andrea Diefenbach)ដើម្បីបង្កើតនូវកម្រងរូបភាព ដែលឆ្លុះបញ្ចាំងអំពីស្ថានភាពជីវិតរបស់ពួកគេផ្ទាល់ បើកបង្ហាញនូវការមើលឃើញរបស់ពួកគេ អំពីពិភពលោក និងផ្តិតយករូបភាពនៃការគិត អារម្មណ៍និងក្តីស្រម៉ៃ ។ តាមរយៈរូបភាពទាំងនេះ ស្ត្រីទាំងឡាយ មានវិធីសាស្ត្រក្នុងការទំនាក់ទំនងនិងតស៊ូមតិនៅក្នុងដៃដែលនឹងដើរតួជាអ្នកបង្ហាញពីរបៀបនៃការផ្លាស់ប្តូរក្នុងសង្គមដើម្បីជាប្រយោជន៍របស់ពួកគេ ។



Phin Romduol
ភិន រំដួល

# THE DAILY LIFE OF A WOMAN
# ជីវភាពប្រចាំថ្ងៃរបស់បងស្រីខ្ញុំ

My elder sister is a factory worker. She is 35 years old. She has five children. Her eldest daughter is 20 years old and is a factory worker. Her second daughter is 18 and is disabled. Her son is 17 and is a construction worker. Her third daughter is 14 and is a student. The youngest son is three months old and was born without a plan. Now she doesn't earn any income since she asked to suspend her work for four months for maternity leave. Her situation is difficult. The earned amount is lower than the expenses, i.e. rent, food, clothes etc. She also has to pay for a nanny. As for her husband, he is a construction worker. He works hard and tries to save money, hoping for a better life.

បងស្រីរបស់ខ្ញុំជាកម្មការិនីរោងចក្រ ។ គាត់មានអាយុ៣៥ឆ្នាំ មានកូនប្រាំនាក់ ក្នុងនោះមានកូនស្រីបីនាក់ និង កូនប្រុសពីរនាក់ ។ កូនស្រីច្បងរបស់គាត់អាយុ ២០ឆ្នាំ ជាកម្មការនីរោងចក្រ ។ កូនស្រីទីពីរ មានអាយុ ១៨ឆ្នាំ ជាជនពិការ ។ កូនប្រុសទីបី មានអាយុ ១៧ឆ្នាំ ជាកម្មករសំណង់ ។ កូនស្រីទីបួនអាយុ ១០ឆ្នាំ ជាសិស្ស ។ កូនទីប្រាំអាយុទើបបាន ៣ខែ ។ គាត់មានកូនចុងក្រោយដោយចៃដន្យ ។ សព្វថ្ងៃគាត់មិនអាចរកប្រាក់ចំនូលបានដោយសារគាត់បានសុំច្បាប់សម្រាលមាតុភាពចំនួនបួនខែ ។
ជីវភាពសព្វថ្ងៃរបស់ពួកគាត់មានការលំបាកព្រោះប្រាក់ចំណូលបានតិចជាងការចំនាយ មានដូចជាថ្លៃជួលបន្ទប់ ការហូបចុក សំលៀកបំពាក់ ទឹកភ្លើង សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ។ ចំណែកប្តីរបស់គាត់ជាកម្មករសំណង់ខំប្រឹងធ្វើការសន្សំប្រាក់ ដោយសង្ឃឹមថាជីវភាពរបស់ពួកគាត់នឹងប្រសើរឡើងជាងនេះ ។























Som Sopheak
សម  សុភ័ក្រ

# OVER-TIME WORK
# សុវត្ថិភាពនិងការងារថែមម៉ោងរបស់កម្មករ

Besides working eight hours a day, workers have to work over time until 6 pm. And in some factories, the workers have to work until 8 pm. After leaving from work, the workers have to buy food, cook rice, wash the dishes and sometimes wash their clothes. They don't have enough sleep. As for the streets, some are very quiet when we leave from work. The access routes are dark, making it hard to commute. Sometimes we don't see the sunlight.

ក្រៅពីធ្វើការក្នុងមួយថ្ងៃ៨ម៉ោង កម្មករនិយោជិតត្រូវធ្វើការថែមម៉ោងរហូតដល់ម៉ោង៦ល្ងាច ហើយរោងចក្រខ្លះទៀត អោយកម្មករនិយោជិតថែមម៉ោង រហូតដល់ម៉ោង៨យប់ ។ បន្ទាប់ពីចេញធ្វើការកម្មករនិយោជិតត្រូវទៅទិញម្ហូប ដាំបាយ លាងចាន និងឆ្លៀតបោកខោអាវ ហើយពួកគាត់ មិនមានពេលគេងគ្រប់គ្រាន់នោះទេ ។ បើនិយាយពីផ្លូវធ្វើដំណើរវិញ ផ្លូវខ្លះស្ងាត់ ឯច្រករោងចក្រតូចៗ គឺងងឹតពិបាកធ្វើដំណើរ ។ ថ្ងៃខ្លះសឹងតែមិនបានឃើញពន្លឺថ្ងៃផង!




LIX






Chea Sarat
ជា សារ៉ាត់

## EVERYDAY LUNCH
## អាហារថ្ងៃត្រង់ជារៀងរាល់ថ្ងៃ

This is the food we always eat at lunch time at 11:20. Since I have come to work six years ago, I have always eaten this kind of food. However, I’m still not used to eating it.

នេះគឺជាអាហារថ្ងៃត្រង់ដែលពួកយើងតែងតែញាំពេលថ្ងៃត្រង់នៅម៉ោង១១និង២០នាទី ។ តាំងពីខ្ញុំចាប់ផ្តើមធ្វើការរយៈពេល៦ឆ្នាំ ខ្ញុំតែងតែញាំអាហារបែបនេះតែខ្ញុំនៅតែមានអារម្មណ៍ថាមិនទាន់ទំលាប់ជាមួយអាហារបែបនេះនៅឡើយទេ ។











Than Chanak
ថាន់ ចាន់ណាក់

# I LOVE FOOTBALL
# ខ្ញុំស្រលាញ់បាល់ទាត់

I love football. I liked it since I was young. Whenever my elder brother is free from work and goes to play football, I ask to go with him. I also wear sports clothes and shoes. I love football and my nation very much. This is my dream. I want to be a footballer. When I was studying, I liked football the most. When there is a football match, my elder brother, his wife, his friends and I go to watch the match. When I watch it, I feel absolutely enthusiastic and want to become a footballer. I will pursue my dream. I love football very very much.

ខ្ញុំស្រលាញ់បាល់ទាត់ ខ្ញុំចូលចិត្តកីឡានេះតាំងពីតូចមកម្លេះ ។ រាល់ពេលបងប្រុសរបស់ខ្ញុំទំនេរពីការងារ គាត់ទៅទាត់បាល់ ខ្ញុំក៏សុំទៅជាមួយគាត់ដែរ ។ ខ្ញុំបានស្លៀកឈុតកីឡា ស្បែកជើងកីឡាទៀតផង ខ្ញុំស្រលាញ់បាល់ទាត់នឹងប្រទេសជាតិខ្លាំងណាស់ នេះជាក្តីស្រម៉ៃរបស់ខ្ញុំដែលខ្ញុំគិតកន្លងមក ខ្ញុំចង់ក្លាយជាអ្នកទាត់បាល់ខ្លាំងណាស់ ។ ពេលនៅសិក្សាខ្ញុំចូលចិត្តបាល់ទាត់ខ្លាំងជាងគេ ដល់ពេលគេប្រកួតបាល់ទាត់ខ្ញុំនិងបងប្រុសព្រមទាំងប្រពន្ធរបស់គាត់នឹងមិត្តភក្តិផ្សេងៗតែងតែទៅមើលការប្រកួតផ្ទាល់ ។ ពេលខ្ញុំមើលហើយមានអារម្មណ៍សែនរំភើប ហើយខ្ញុំចង់ក្លាយអ្នកកីឡាបាល់ទាត់ ។ ខ្ញុំនឹងធ្វើអោយក្តីស្រម៉ៃក្លាយជាការពិត ។ ខ្ញុំស្រលាញ់បាល់ទាត់ខ្លាំងណាស់ៗ..... ។


Jeep






AIA


macron






AIRWAYS






Et Voleak
អ៊ិត វល័ក្ខ

# A STRUGGLING LIFE FOR MY MOTHER
# ជីវិតតស៊ូដើម្បីម្តាយ

I have been far away from my mother in order to earn money. Mom works hard. She has raised the children, and even the grandchildren. Mom does the housework, too. I feel sorry for my mother. I will do anything to support her. I work, and after work I study part-time. I don't have enough time to rest. I struggle in the rain to improve my family situation. It's difficult for me both physically and emotionally, but I will keep trying. I won't be discouraged. I want to live happily together and see your smile every day, Mom. What you have given me is my life, body and organs. This is already great! I don't want anything else. I'm very lucky to be your daughter. I will try to study to improve our life. My tiredness can't be compared with yours: You have raised me since I was little until I have grown up. Thank you so much, Mom. My love for you will never end.

កូនបានឃ្លាតឆ្ងាយពីអ្នកម្តាយដើម្បីជួយរកប្រាក់ជួយសម្រាលបន្ទុករបស់អ្នកម្តាយ ។ កូនមិនបានជួយកិច្ចការអ្នកម្តាយទៀតឡើយ កូនព្រួយបារម្ភណ៍អំពីសុខភាពអ្នកម្តាយគ្រប់ពេលវេលាអ្នកម្តាយខិតខំធ្វើការទាំងឈឺទាំងជាក៏ព្រោះតែកូនៗ អ្នកម្តាយពុះពារគ្រប់ឧបសគ្គធ្វើការគ្រប់បែបយ៉ាងដើម្បីគ្រួសារ អ្នកម្តាយបានចិញ្ចឹមកូនរហូតដល់ចិញ្ចឹមចៅៗថែមទៀត ។ ហើយមិនតែប៉ុណ្ណោះ អ្នកម្តាយឆ្លៀតធ្វើកិច្ចការផ្ទះថែមទៀត ខ្ញុំអាណិតម្តាយរបស់ខ្ញុំខ្លាំងណាស់ ខ្ញុំនិងធ្វើអ្វីៗដើម្បីអ្នកម្តាយរបស់ខ្ញុំ ។ ខ្ញុំធ្វើការ ហើយពេលចេញពីធ្វើការ ខ្ញុំឆ្លៀតទៅរៀនក្រៅម៉ោង ។ ខ្ញុំគ្មានពេលសម្រាកគ្រប់គ្រាន់ឡើយ ខ្ញុំតស៊ូកាត់ភ្លៀងរលឹម ធ្វើយ៉ាងណាអោយជីវិតគ្រួសារមានភាពល្អប្រសើរឡើង ។ ខ្ញុំលំបាកទាំងចិត្តទាំងកាយ ស៊ូទ្រាំអត់ធ្មត់បន្តទៅទៀត ខ្ញុំមិនរាថយឡើយ ។

កូនចង់រស់នៅដោយមានសុភមង្គលជាមួយក្រុមគ្រួសារហើយមើលឃើញនូវស្នាមញញឹមរបស់អ្នកម្តាយរៀងរាល់ថ្ងៃ ។អ្នកម្តាយ! អ្វីដែលអ្នកម្តាយបានផ្តល់អោយកូនគឺជីវិត រាងកាយនិង អវៃយវៈគឺគ្រប់គ្រាន់ហើយ កូនមិនចង់បានអ្វីទៀតហើយ ។ កូនមានសំណាងណាស់បានកើតជាកូនអ្នកម្តាយ ។ កូននឹងប្រឹងប្រែងរៀនសូត្រដើម្បីអោយជីវិតពួកយើងបានប្រសើរ ។ ការនឿយហត់របស់កូនមិនស្មើរនិងការនឿយហត់របស់ម្តាយដែលបានចិញ្ចឹមបីបាច់កូនតាំងពីតូចរហូតមកដល់ធំ ។ កូនអរគុណណាស់អ្នកម្តាយ ។ កូនស្រលាញ់អ្នកម្តាយអស់ពីបេះដូង ។ កូនស្រលាញ់អ្នកម្តាយលុះថ្ងៃសូន្យ!
















Time Zones
Time Zones
Time Zones
Time Zones
Boost!













Chan Phaktra
ចាន់ ភក្ត្រា

# WASTE AROUND THE PLACE WHERE I LIVE

# សំរាមនៅជុំវិញកន្លែងដែលខ្ញុំរស់នៅ

When I go to work or come back from work, I always see a lot of trash along the road or around the rental house. When I take photos of it, I think it will allow a lot of people to see and help to contribute to the change. This is particularly for the owner of the rental house. I would like to suggest that they provide a trashcan with a lid to cover so that there will be no bad smell in the environment. It is just my request. This is because those who rent the house in that area pay 2000 to 4000 riels per room for trash collection services.

ពេលខ្ញុំទៅធ្វើការឬពេលត្រលប់មកពីធ្វើការវិញខ្ញុំតែងតែឃើញសំរាមជាច្រើននៅតាមដងផ្លូវឬជុំវិញផ្ទះជួល ។ ពេលខ្ញុំថតរូបនេះខ្ញុំគិតថាវាអាចអោយមនុស្សជាច្រើនឃើញហើយជួយចូលរួមនិងកែតម្រូវជាពិសេសម្ចាស់ផ្ទះជួល ដែលខ្ញុំបានសំណូមពរ អោយគាត់ដាក់ធុងសំរាមដែលមានគម្របបិទជិតដើម្បីកុំអោយមានខ្លិនស្អុយចេញមកក្រៅ ។ នេះគ្រាន់ជាការស្នើរសុំ ព្រោះអ្នកជួលផ្ទះនៅក្នុងតំបន់នោះពួកគាត់ក៏បានបង់ថ្លៃសេវាសំរាមក្នុងមួយបន្ទប់ចាប់ពី ២000៛ ទៅ ៤000៛ ។











Hem Sela
ហែម សិលា

# THE RENTED HOUSE OF ME AND MY FRIENDS
# កន្លែងរស់នៅរបស់ខ្ញុំនិងមិត្តរបស់ខ្ញុំ

With these pictures, I would like to present the living situation of me and my friends in our rented room. The pictures show activities my friends and I do every day after work. My friends and I have very little time to chat because we work over-time every day. What's important is that my friends and I don't want to live like this. We want a place with certain standards; i.e. with enough equipment and a bathroom inside, with enough space to live in and for an acceptable rent. After I had moved here, they were the first people I started to know. They are kind and helpful when there are problems.

រូបភាពទាំងអស់នេះគឺខ្ញុំចង់បង្ហាញពីស្ថានភាពរស់នៅរបស់ខ្ញុំនិងមិត្តដែលរស់នៅក្នុងបន្ទប់ជួល ។ រូបភាពនេះគឺជាសកម្មភាព ដែ ល ពួកយើងធ្វើជារៀងរាល់ថ្ងៃពេលត្រលប់មកពីធ្វើការវិញ ។ ពួកយើងមានពេលតិចណាស់ក្នុងការនិយាយគ្នាលេង ដោយសារត្រូវ ធ្វើការថែមម៉ោងរាល់ថ្ងៃ ។ អ្វីដែលសំខាន់ ពួកយើងមិនចង់រស់នៅក្នុងសភាពបែបនេះទេ គឺចង់បានកន្លែងរស់នៅដែលមាន ផាសុ កភាព មានបន្ទប់ទឹកទូលាយហើយនៅក្នុងបន្ទប់ស្រាប់ និងគ្រឿងបរិក្ខារប្រើប្រាស់គ្រប់គ្រាន់ និងមានតម្លៃជួលសមរម្យ ។ ចាប់ពីពេលដែលខ្ញុំបានមកនៅទីនេះ មិត្តរបស់ខ្ញុំគឺជាមនុស្សដំបូងដែលខ្ញុំបានស្គាល់ ពួកគាត់ជាមនុស្សមានចិត្ត និងចេះជួយយក អាសារនៅពេលដែលខ្ញុំមានបញ្ហា ។

















Yang Chenda
យ៉ាង ចិន្តា

# LIFE AND DREAM
# ជីវិតនិងក្តីស្រមៃ

My name is Yang Chenda. I am from a farmer family in Takeo province. I have left my family to work as a factory worker in Phnom Penh over ten years ago. Today there is a chance for me to tell the public about my situation through GIZ. As for these photos, I would like to show that my salary is $200, for which I have to work for ten hours every day. Although I do not like to work this way, I have to pay my room rent and utility with an amount of $50 and buy clothes, daily-use materials, food and medicine. I also have to send the money to my parents for their health treatment and debt payment. I always dream that I will be able to live with my family in the future in a proper shelter and with enough food to eat, just like other people who are also workers like me. Is it possible?

នាងខ្ញុំឈ្មោះ យ៉ាង ចិន្តា ជាកូនកសិករមកពីខេត្តតាកែវ ។ ឃ្លាតឆ្ងាយពីគ្រួសារមកភ្នំពេញ ធ្វើការជាកម្មការនីរោងចក្រអស់រយពេលជាង១០ឆ្នាំ ។ ថ្ងៃនេះជាឱកាសមួយដែលនាងខ្ញុំអាចបង្ហាញនូវស្ថានភាពរបស់ខ្ញុំ តាមរយៈ GIZ ដល់សាធារណៈជន ។ រូបថតទាំងនេះខ្ញុំចង់បង្ហាញថា ខ្ញុំធ្វើការទទួលបានប្រាក់ខែ ២០០$ ដោយធ្វើការ ១០ម៉ោងជារៀងរាល់ថ្ងៃ ។ ខ្ញុំហាក់មិនពេញចិត្តនិងស្ថានភាពបែបនេះទេព្រោះត្រូវចំណាយទៅលើថ្លៃបន្ទប់ជួល ទឹកភ្លើង សរុប៥០$ ក្រៅពីនេះក៏ត្រូវចំនាយលើសំលៀកបំពាក់ សម្ភារៈប្រើប្រាស់ប្រចាំថ្ងៃអាហារ ថ្នាំពេទ្យ ផ្ញើអោយឪពុកម្តាយ ដើម្បីព្យាបាលជំងឺ និងសងបំណុល ។ ខ្ញុំតែងស្រម៉ៃថា ថ្ងៃអនាគតខ្ញុំ និងបានរស់នៅជុំគ្នាជាមួយគ្រួសារមានការហូបចុកគ្រប់គ្រាន់ មានជម្រកសមរម្យ មិនខុសពីមនុស្សដទៃ ដែលមិនមែនជាកម្មកររោងចក្រដូចខ្ញុំ ។ តើអាចទេ?









GUCCI











Chin Sambath
ចិន សម្បត្តិ

# RENTED ROOMS
# បន្ទប់ជួល

Daily living situations of workers are difficult because the monthly income is only $205-$235. The room rental fee is $30-$45, but it is not clean. Moreover, the owner never comes to check the room with broken or lost equipment. This has to be repaired on personal expense. Example single room: Rental fee is $20. She lives alone. She is 23 years old. Her salary is $195-$218, of which $45-$50 is sent home. The rest is spent for food and clothes. Example family room: Rental fee is $30 She lives with her family, and she has two children. Her husband is a driver and earns $130-$150 per month while his wife earns $187-$215. The husband is 27 years old, and the wife is 23. The total income is $340-$365. They support their families on both sides with $10-$15 per month. The rest is for food.

ស្ថានភាពរបស់កម្មករជារៀងរាល់ថ្ងៃមានការពិបាកច្រើនពីព្រោះមានចំណូលក្នុង១ខែបានត្រឹមពី ២០៥$ ទៅ ២៣៥$ ។ ចំណែកបន្ទប់ជួលមានតម្លៃជួលពី ៣០$ ទៅ ៤៥$ ជាប្រភេទបន្ទប់មិនសូវស្អាត ហើយម្ចាស់ផ្ទះក៏មិនដែលមកមើលបន្ទប់ នៅពេលដែលបន្ទប់ខូចរឺបាត់បង់វត្ថុអ្វីៗនៅក្នុងបន្ទប់ទេគឺត្រូវចំណាយផ្ទាល់ខ្លួន ។
ឧទាហរណ៍ការរស់នៅក្នុងបន្ទប់ជួលម្នាក់ឯង ៖ បន្ទប់ជួលមានតម្លៃ២០$ ។ អ្នកជួលមានអាយុ២៣ឆ្នាំ ទទួលបានប្រាក់ ១៩៥$ ទៅ ២១៨$ ត្រូវចំណាយ ៤៥$ ទៅ ៥០$ ។ លុយដែលនៅសល់ប៉ុន្មានត្រូវចំណាយលើការហូបចុកប្រចាំថ្ងៃ ហើយទិញសំលៀកបំពាក់ការប្រើប្រាស់ ។

ឧទាហរណ៍ការរស់នៅក្នុងបន្ទប់ជួលជាមួយគ្រួសារ ៖ បន្ទប់ជួល មានតម្លៃ៣០$ សមាជិកគ្រួសារមានប្តីប្រពន្ធ និងកូនពីរនាក់ ។ ប្តីជាអ្នកបើកឡានក្នុង១ខែបានប្រាក់ខែ ពី ១៣០$ ទៅ ១៥០$ ។ ចំណែកប្រពន្ធទទួលបានប្រាក់ខែ ១៨៧$ ទៅ ២១៥$ ។ ប្តីអាយុ២៧ឆ្នាំ ប្រពន្ធអាយុ២៣ឆ្នាំ ចំនួលទាំងពីរនាក់ទទួលបាន២៤០$ទៅ៣៦៥$ ហើយគាត់ចំណាយនៅលើឪពុកម្តាយទាំងសងខាងក្នុង១ខែ ១០$ ទៅ ១៥$ នៅសល់ប៉ុន្មានគាត់ ចំណាយលើការហូបចុកប្រចាំថ្ងៃ ។








## About SLSG
## អំពី គម្រោងវាយនភណ្ឌបទដ្ឋានសង្គមនៅក្នុងតំបន់អាស៊ី

The project Social and Labour Standards in the Textile and Garment Sector in Asia (SLSG) is implemented by the Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH, which works on behalf of the German Federal Ministry for Economic Cooperation and Development (BMZ). The project is working in Bangladesh, Cambodia, Myanmar and Pakistan and together with China, supporting the efforts of private and state actors to improve sustainability standards in the textile and garment sector.

គម្រោងវាយនភណ្ឌបទដ្ឋានសង្គមនៅក្នុងតំបន់អាស៊ី (SLSG) គឺកំពុងត្រូវបានអនុវត្ត ដោយភ្នាក់ងារអភិវឌ្ឍន៍ GIZ ដែលកំពុងធ្វើការក្នុងនាមនិងតំណាងអោយ ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍នៃរដ្ឋាភិបាលរបស់អាឡឺម៉ង់ (BMZ) ។ គម្រោងនេះកំពុងធ្វើការក្នុងប្រទេសចំនួនប្រាំដូចជា កម្ពុជា បង់ក្លាដេស ភូមា ប៉ាគីស្ថាន និងប្រទេសចិន ដែលរួមគ្នាគាំទ្រលើវិស័យឯកជននិងរដ្ឋក្នុងកិច្ចខំប្រឹងប្រែងដើម្បីពង្រឹងនូវស្តង់ដារនិរន្តភាពនៅក្នុងវិស័យវាយនភណ្ឌនិងរោងចក្រ ។

## About WIC
## មណ្ឌលព័ត៌មានកម្មករ (WIC)

Worker’s information Center (WIC) is the women garment workers based association and registered at Ministry of Interior (MOI) in 2009. WIC was emerged from the Women’s Agenda for Change (WAC) project called the garment workers’ empowerment. WIC supports women garment workers to advocate for and realize their rights. WIC’s long term strategy focuses on building and strengthening a movement of garment workers towards realization of accountable and legitimate leadership within the sector, which responds to women worker’s rights and needs.

មណ្ឌលព័ត៌មានកម្មករ (WIC) គឺជាសមាគមដែលផ្តោតលើកម្មកររោងចក្រដែលជាស្រ្តី ហើយបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ(MOI) នៅក្នុងឆ្នាំ២០០៩ ។ មណ្ឌលពត៌មានកម្មករ បង្កើតមកពីគម្រោងមួយនៃរបៀបវារៈរបស់ស្រ្តីដើម្បីការផ្លាស់ប្តូរដែលគេហៅថា គម្រោងជំរុញ និងលើកកម្ពស់កម្មកររោងចក្រ ។

សមាគមមណ្ឌលព័ត៌មានកម្មករគាំទ្រស្រ្តីកម្មកររោងចក្រអោយចេះតស៊ូមតិនិងស្គាល់ពីសិទ្ធិរបស់ពួកគាត់ ។

សមាគមន៍មណ្ឌលព័ត៌មានកម្មករ មានយុត្តិសាស្រ្តរយៈពេលវែងគឺផ្តោតទៅលើការស្ថាបនា និងពង្រឹង ចលនាកម្មកររោងចក្រឆ្ពោះទៅការទទួលស្គាល់ប្រកបដោយភាពទទួលខុសត្រូវ និងក្នុងភាពជាអ្នកដឹកនាំដោយស្របច្បាប់នៅក្នុងវិស័យរោងចក្រដែលឆ្លើយតបទៅនឹងតម្រូវការ និងសិទ្ធិរបស់កម្មករដែលជាស្រ្តី ។



© thekla ehling

**Andrea Diefenbach** is a freelance photographer. She studied at the University of Applied Science in Bielefeld, works with German and international magazines and organizations, as well as on her personal long-term projects. For her critical and incisive reflection of social situations she has received several prizes, such as the Photographic Museum of Humanity Grant, 2014; n-ost-Reportage Prize, 2012; and Abisag-Tüllmann Prize, 2013. Andrea teaches photography at the Lucerne University of Applied Sciences and Arts, Switzerland.

លោកស្រី អ៊ែនទ្រា ឌីហ្វេនបាច គឺជាងថតឯករាជ្យ ។ ( **Andrea Diefenbach** ) លោកស្រីបានសិក្សានៅសាកលវិទ្យាល័យ Applied Science in Bielefeld ។ លោកស្រីធ្វើការជាមួយស្ថាប័ននិងទស្សនាវដ្ដីជាច្រើននៅអាល្លឺម៉ង់និងបណ្ដាប្រទេសនានា ។ ដោយសារការថតរូបរបស់លោកស្រីបានឆ្លុះបញ្ចាំងអំពីស្ថានភាពសង្គមហើយ លោកស្រីបានទទួលពានរង្វាន់ជាច្រើនដូចជា Photographic Museum of Humanity Grant, 2014; n-ost-Reportage Prize, 2012; and Abisag-Tüllmann Prize, 2013 ។ លោកស្រីក៏បានបង្រៀនមុខវិជ្ជាថតរូបនៅ Applied Sciences and Arts ក្នុងប្រទេសស្វីសផងដែរ ។

**Published by the**
Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Registered offices
Bonn and Eschborn, Germany

Social and Labour Standards in the Textile
and Garmet Sector in Asia (SLSG)
No 17, Street 306, Boeung Keng Kang 1
Phnom Penh, Cambodia
Phone +855 23 860 110
giz-kambodscha@giz.de
www.giz.de/cambodia

**As at**
February 2018

**Layout**
Eva Hofmann, Katrin Straßburger - W4 Būro für Gestaltung, Frankfurt

**Photo credits**
Title, group picture and portraits of workers: Andrea Diefenbach
Photographs taken by participants of the Participatory Photography Project,
printed with permission

**Text**
Introductory text: Irene Genzmer
Explanatory texts to the photographs written by participants of the
Participatory Photography Project, printed with permission

GIZ is responsible for the content of this publication.

On behalf of the
German Federal Ministry for Economic Cooperation and Development (BMZ)